

# បទអប់រំខ្លី

## ស្តីអំពី: អត្ថន័យនៃបុណ្យវិសាខបូជា

( ព.ស២៥៥៧-២៥៥៨ )

## កម្មវិធីណាជីសំឡេងព្រះធម៌

## វត្តប្រាសាទស្រះកណ្តាល( ខ្ចាស់ )

*នេះគឺជា អភិលក្ខិតសម័យប្រកបដោយសិរីមហានក្ខត្តឫក្ស ។ ជាឱកាសប្បវត្តិ នៃបុណ្យវិសាខបូជា ដែលពុទ្ធសាសនិកជនមានចំនួនប្រមាណ ១ពាន់លានអង្គនាក់ទូទាំងជុំវិញពិភពលោកពេញទឹកចិត្តសោមនស្ស និងទឹកចិត្តបូជនកម្មចំពោះព្រះសាក្យមុនីសម្មាសម្ពុទ្ធជាផ្លូវមួយ នាំគ្នាប្រារព្ធធ្វើកម្មវិធីបុណ្យនេះឡើង អស់ចិរកាល២៦ពុទ្ធសតវត្សរ៍មកហើយ ។ បុណ្យនេះ បានក្លាយទៅជាបុណ្យពុទ្ធសាសនាបែបអន្តរជាតិ ដោយសេចក្តីសម្រេចរបស់មហា*

សន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៩ ក្នុងគោលដៅផ្សព្វផ្សាយមេត្តាធម៌ ការស្រឡាញ់សន្តិភាព និងការរំឭកគុណព្រះពុទ្ធ ។ បណ្តាពុទ្ធមាមកជន ជុំវិញពិភពលោកចម្រុះជាតិសាសន៍ទាំងប្រមាណ ១ ពាន់លានអង្គនាក់នោះ ប្រជាជនជាពុទ្ធបរិសទ្យតាមបណ្តាប្រទេសនីមួយៗ បានទន្ទឹងរង់ចាំនូវ កាលានុវត្តភាព(ឱកាស)នេះ មានរយៈពេលមួយឆ្នាំជារៀងរាល់ឆ្នាំ ទម្រាំបានយង់យល់ភប់ប្រសព្វដូចបំណង, លុះថ្ងៃកំណត់បុញ្ញកាលចូលមកដល់ ទើបរៀបចំចាត់ចែងត្រៀមទុកជាស្រេចស្រាប់ នូវគ្រឿងប្រដាប់ប្រដាបូជា គ្រឿងប្រទីបជ្វាលា គ្រឿងទ្រោលបំភ្លឺ ទៀនធូបផ្កាភ្ញីគ្រឿងគន្ធពិដោរគ្រអូបឈ្ងុយឈ្ងប់ផ្សេងៗ យ៉ាងសម្រិតសម្រាំងល្អឥតខ្ចោះ ទៅតាមទម្រង់បរិបទវប្បធម៌ អារ្យធម៌ប្រពៃណី និងទំនៀមទម្លាប់នៃប្រទេសទីទៃៗរៀងៗខ្លួន ។

ដូចគ្នានឹងពុទ្ធសាសនិកក្នុងតំបន់និងពិភពលោកដែរ នៅក្នុងឱកាសនេះ វេលានេះ ថ្ងៃនេះ ប្រទេសខ្មែរដែលជាប្រទេសពហុអច្ឆរិយៈមួយ ធ្លាប់បានទទួលយក និងគោរពរាប់អានព្រះពុទ្ធសាសនាជាង ២៦៣.ស.កន្លងមកហើយដែរ

នោះ ពុំបានបោះបង់ចោលលះបង់ចោលអបចាយនកម្ម ឬធ្វើពើដើយបំភ្លេចនូវតួនាទី កាតព្វកិច្ចរបស់ពុទ្ធសាសន ពន្ធុវង្ស(ផៅសន្តាននៃព្រះពុទ្ធសាសនា)ឡើយ ពោលគឺ ប្រទេសមួយនេះ សម្ផិតសម្ផាំងប្រជាប់តាក់តែងខ្លួនប្រាណ យ៉ាងរៀបរយរួសរាន់ ដើម្បីទទួលនូវការគម្រប់២៦៣៧ឆ្នាំ នៃអភិលក្ខិតកាលបុណ្យវិសាខបូជា ។ បណ្តាខេមរជន ប្រមាណ៩០ភាគរយនៃប្រជាជនសរុប គឺស្មើនឹងប្រជា ពលរដ្ឋ១៣លាន៥សែននាក់ លើប្រជាពលរដ្ឋ ១៥លាន នាក់ បានចូលរួមប្រារព្ធនូវបុញ្ញកម្មនេះដោយសទ្ធាដោយ ការស្ម័គ្រចិត្ត ជាសន្ទស្សន៍បញ្ជាក់ឲ្យឃើញថា ពូជខ្មែរ ឥតភ្លេចជាតិកំណើតខ្លួនឡើយ ពូជខ្មែរឥតភ្លេចវប្បធម៌ អរិយធម៌របស់ជាតិខ្លួនឡើយ ពូជខ្មែរឥតភ្លេចពុទ្ធសាសនា ដែលជាសាសនាសន្តិភាពរូបនីយកម្មលេខ១ក្នុងលោកឡើយ ពូជខ្មែរឥតភ្លេចជាតិសាសនាព្រះមហាក្សត្ររបស់ខ្លួនឡើយ បើខ្មែរណាភ្លេច ខ្មែរនោះមានមារយាទអន់ថយជាងសត្វ តិរច្ឆានទៅទៀត ។

ព្រោះហេតុនោះ ទើបយើងក្រឡេកឃើញនូវសកម្ម-ភាព និងកាយវិការដ៏រស់រវើកនៃប្រជាពុទ្ធបរិស័ទមានចំនួនយ៉ាងច្រើនក្នុងប្រទេសដ៏តូចច្រឡឹងមួយនេះ ដូចជានៅក្នុងទីវត្តអារាមត្រង់ខ្លោងទ្វារ ព្រះវិហារ ទីលានព្រះចេតិយព្រះស្រីមហាពោធិព្រឹក្ស ត្រូវបានតុបតែងរចនាយ៉ាងល្អល្អះដោយគ្រឿងប្រទីបផ្កាលា ភ្លើងពណ៌លម្អច្រេទាលបំភ្លឺ និងផ្កាភ្ញីផ្កាកម្រងក្រអូបសាយសព្វ, មានភ្លេងពិណពាទ្យចាក់ប្រគំណិងណុងពីរោះរណ្ដំរងំ, មានសទ្ទបទនមស្ការថ្វាយបង្គំព្រះរតនត្រ័យសូធ្យប្រជេញបណ្ដាក់ទម្ងាក់តៗគ្នាទ្រហឹងមានសំឡេងព្រះសង្ឃចម្រើនព្រះបរិត្ត បញ្ចៀសភយន្តរាយឮលាន់ខ្ទរខ្ទាររំពងដ៏យ៉ាងស្រួះស្រួលរំជួលសោតា, លុះព្រះទិនករជ្រេទេរទាបស្រយុតចុះទៅ បទឧគ្ឃោសនសព្ទបទប្រកាសជយឃោស បទស្មូធ្យមានបែបផ្សេងៗទាក់ទងទៅនឹងអតីតប្បវត្តិរបស់ព្រះពុទ្ធនិងសាវ័កសាវិកា បានលេចឮគឹកកងរំពងខ្ទរខ្ទាយគ្រប់វត្តអារាមទាំងអស់ នៃព្រះរាជា-ណាចក្រកម្ពុជា ។ ដោយឡែក នៅឯនាយតាមដងផ្លូវ ដងមហាវិថីក្នុងក្រុងនិងបណ្ដាខេត្តខ្លះ ថែមទាំងមានព្រះសង្ឃ

ឧបាសក ឧបាសិកា ដូនជី តាជី យុវជន យុវតី កុមារា កុមារី ដែលជាពុទ្ធសាសនិក ពុទ្ធសាសនិកា បានហែហមធម្មយាត្រាដោយមានទង់ជាតិ ទង់សាសនា ព្រះបដ ព្រះពុទ្ធរូប ព្រះសារីរិកធាតុ រួមទាំងគ្រឿងឧគ្ឃោសនោបករណ៍ ហើយនិងអមដំណើរដោយយានយន្ត ទោចក្រយាន បានសូធ្យស្វាធ្យាយព្រះធម៌ ស្រែកប្រកាសនូវពុទ្ធប្បវត្តិដ៏ទ្រហឹងអឺងកងរំពងគួរឲ្យស្ញប់ស្ញែង ដើម្បីបញ្ជ្រាបនូវធម៌អហិង្សានិងធម៌រួបរួមសាមគ្គីភាព ក្នុងឱកាសបុណ្យយ៉ាងមហោឡារិកនេះឲ្យមហាជនបានយល់ដឹងអំពីគុណតម្លៃពិតៗ ។ ទិដ្ឋភាពដ៏ស្រស់ត្រកាលនេះ, បើក្រឡេកមើល បដា ទង់សាសនា ទង់ជាតិដែលកំពុងតែក្រោកឈរបក់ផាយផាត់រលាស់រវិចៗក្រោមដំនោរនិរតីនៃខែពិសាខ បន្ទោរបន្ទន់ខ្លួនដង្ហោយហៅពុទ្ធបរិសទ្យទាំងអស់ ឲ្យនាំគ្នាសាងអំពើល្អចំពោះសង្គមប្រកាន់យកធម៌មេត្តា គោរពសិទ្ធិមនុស្សសត្វទូទៅ ដែលការណ៍នេះសុទ្ធតែជានិមិត្តរូបនៃធម្មានុកូលភាព ។

លក្ខណសម្បត្តិ ដែលបណ្ដាលឲ្យពុទ្ធសាសនិកនិងពាហិរសាសនិកបរិសទ្យទូទាំងពិភពលោក ផ្ដើមធ្វើបុណ្យ

វិសាខបូជានេះឡើង ព្រោះមានអត្ថន័យ៣ចំណុចសំខាន់ៗ ដែលយើងត្រូវចេះដឹងជាចាំបាច់គឺៈ

**ទី១.និក្ខមនកាលៈ** គឺកាលដែលព្រះអង្គទ្រង់ប្រសូតជាពេលវេលាដ៏មានសិរីនក្ខត្តឫក្សមួយ ដែលពិភពលោកទទួលបាននូវថ្ងៃកំណើតរបស់ព្រះពុទ្ធជាម្ចាស់ ដែលទ្រង់ប្រសូតក្នុងថ្ងៃសុក្រ ខែពិសាខ ឆ្នាំច ក្នុងឧទ្យានលុម្ពិនី ក្រោមដើមសាលព្រឹក្ស ជាទីចន្លោះនៃនគរកបិលពស្តុនិងនគរទេវទហៈ ដែនសក្កៈ ប្រទេសឥណ្ឌា (បច្ចុប្បន្នប្រទេសនេប៉ាល់), ព្រះវរបិតាព្រះនាមសុទ្ធោទនៈ ព្រះវរមាតាព្រះនាមមាយាទេវី ត្រកូលសក្យវង្ស ហើយមានព្រះនាមថា "**សិទ្ធត្ថ**"។



**ជី២.បរមាភិសម្ពោធិកាលៈ** គឺកាលដែលព្រះ-សិទ្ធត្ថត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ជាពេលវេលាដ៏មានសិរីនក្ខត្តឫក្សមួយទៀត ដែលពិភពលោកទទួលបាននូវព្រះធម៌ជាសភាវៈទ្រទ្រង់លោក ជាយន្តការសាងនូវសេចក្ដីសុខ ជាសេណារិយោរំលត់ទុក្ខចូលទៅកាន់ព្រះនិព្វាន, ព្រះសយម្ភូញាណទ្រង់បានត្រាស់ដឹងនូវព្រះធម៌នេះ ក្រោយពីព្រះអង្គលះបង់នូវទ្រព្យសម្បត្តិដ៏មហិមា ហើយយាងចេញសាងអភិនេស្រ្កមន៍ ធ្វើទុក្ករកិរិយាត្រឡប់មកប្រព្រឹត្តធម៌មជ្ឈិមបដិបទាបានចាក់ធ្លុះនូវសច្ចធម៌ ហើយទ្រង់ត្រាច់ចរប្រកាសសាសនាប្រោសវេនេយ្យសត្វ ដោយពុទ្ធកិច្ច៥យ៉ាងអស់ថិរវេលា៤៥ព្រះវស្សា គឺចាប់ផ្ដើមប្រកាសពីព្រះជន្ម៣៥វស្សា រហូតដល់ព្រះជន្ម៨០វស្សាត្រាតែមានពុទ្ធបរិសទ្យទាំង៤ គឺភិក្ខុ ភិក្ខុនី ឧបាសកឧបាសិកាគ្រប់គ្រាន់អាច ទ្រទ្រង់អាចផ្សព្វផ្សាយព្រះពុទ្ធ-សាសនាជំនួសព្រះអង្គ ដរាបសុសសាយពេញពិភពលោកបាន, ព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងនូវចតុរារិយសច្ចនេះក្នុងវេលាបច្ឆិមកាល ក្រោមម្លប់ពោធិព្រឹក្ស នៅថ្ងៃពុធ

ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា ក្បែរស្ទឹងនេរញ្ជរា នាមណ្ឌលគយា ដែលសព្វថ្ងៃហៅថា "**ពុទ្ធគយា**" ក្នុងរដ្ឋពិហារ ប្រទេសឥណ្ឌា ។



**ឌី៣.បរិនិព្វានកាលៈ** គឺកាលបរិនិព្វាននៃព្រះតថាគតជាម្ចាស់, ចាប់ពីព្រះអង្គទ្រង់ប្រសូតគ្រប់ព្រះជន្មសោយរាជ្យហើយលះចោលនូវសម្បត្តិនោះៗ និងចាប់ពីព្រះអង្គយាងចេញសាងអភិនេស្ក្រមន៍ធ្វើទុក្ករកិរិយា ហើយត្រឡប់មកប្រព្រឹត្តធម៌មជ្ឈិមបដិបទាបានចាក់ធ្លុះនូវសច្ចធម៌និងតមកទៀត ទ្រង់សម្ដែងធម៌ប្រោសប្រាណសព្វសត្វឲ្យបានសម្រេចអមតទ្រព្យជាអនេកអនន្តមក, ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅកាន់ក្រុងកុសិនារា ហើយចូលកាន់ព្រះនិព្វាននៅថ្ងៃអង្គារ ពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ ក្រោមម្លប់ដើមសាលព្រឹក្ស ក្នុងបច្ចូសសម័យ នាឧទ្យាននៃ មល្លក្សត្រក្នុងព្រះនគរនោះតែម្ដង, ការយាងចូលកាន់បរិនិព្វាននេះបណ្ដាលឲ្យមនុស្សនិងទេវតាទាំងឡាយក្នុងចក្រវាឡទាំងមូលរំជួលចិត្តសោកស្ដាយជាពន់ពេក ។

កាលទាំង៣នេះ ជាចំណារដ៏សំខាន់ដែលបកស្រាយរ៉ាយរ៉ាប់បើកបង្ហាញពីព្រះចរិយា ព្រះសកម្មភាព ព្រះពុទ្ធ-តួនាទីនៃព្រះពុទ្ធអង្គឲ្យពិភពលោកស្គាល់ព្រះអង្គថា ទ្រង់ពុំមែនជាបុគ្គល**អាត្មានិយម**ដោយដាច់ខាត ហើយថាទ្រង់




ជាបុគ្គលសុទិដ្ឋិនិយមបំផុតមានព្រះធម្មសម្បត្តិល្អឯកបំផុត មានព្រះហឫទ័យមេត្តាបរិសុទ្ធជាងគេបំផុតនៅក្នុងលោក ។

កំណាត់ចំណារដ៏សំខាន់នេះ មិនមែនជាទីគោរពរាប់អាននៃពុទ្ធសាសនិកក្នុងតំបន់តែប៉ុណ្ណោះទេ តែក៏ជាទីគោរពរាប់អាននិងជាទីទទួលស្គាល់របស់ UN (UNITED

NATION)ទៀតផង ដូចសេចក្ដីសម្រេចនៃមហាសន្និបាតអង្គការUNនោះជាឧទាហរណ៍ស្រាប់ ។ ជាក់ស្ដែង នៅក្នុងក្រឹត្យមាត្រានៃអង្គការសហប្រជាជាតិ បានចែងដាក់បញ្ចូលនូវគោលការណ៍របស់ព្រះពុទ្ធសាសនា រួមមានធម៌អហិង្សាសិទ្ធិមនុស្ស សេរីភាព ការអប់រំ និងសីលធម៌ជាដើម ដើម្បី**សន្តិសហវិជ្ជមាន**ក្នុងពិភពលោកទាំងមូល ។

ការដាក់បញ្ចូលនូវគោលការណ៍នៃព្រះពុទ្ធសាសនារបស់អង្គការសហប្រជាជាតិនេះមិនមែនចៃដន្យឡើយ គឺអាស្រ័យដោយ**សំយោគទស្សនន័យ**៣ប្រការជាចម្បង រួមមាន៖

**ចំ១.សាសនបុព្វសិទ្ធិ:** អង្គការនេះបានឲ្យតម្លៃជាពិសេសខាងការគោរពសិទ្ធិ សេរីភាពសាសនា សេរីភាពជំនឿ ពុទ្ធទំនៀម ពុទ្ធលទ្ធិ ច្បាប់សាសនា និងបរិបទនៃការប្រតិបត្តិតាម**បុព្វសិទ្ធិ**របស់ព្រះពុទ្ធសាសនា ។ ការលើកតម្កើងនិងការផ្ដល់នូវ**ឱកាសទាន**(ការបើកសិទ្ធិ)នេះ ដោយហេតុយល់ឃើញថា តាមធម្មតា សាសនាឬទំនៀមទម្លាប់នៃជាតិសាសន៍មួយ តួយ៉ាងដូចព្រះពុទ្ធសាសនានេះជា

ដើមតែងត្រូវបានពុទ្ធសាសនិកស្រឡាញ់គោរពរាប់អាន ប្រតិបត្តិប្រចាំត្រកូលប្រចាំជាតិប្រចាំប្រទេសដ៏យ៉ាងខ្ជាប់ខ្ជួន បានវិវឌ្ឍចាក់ឫសគល់លូតលាស់ចូលទៅក្នុងផ្នត់គំនិត នៃ **សទ្ធិកជន**គ្រប់ៗរូបស្រេចបាត់ទៅហើយ ព្រោះហេតុនោះពុំមាននរណាអាចបញ្ឈប់ ឬបង្ខិតបង្ខំឲ្យពួកគេបោះបង់ចោលនូវលទ្ធិនេះបានឡើយ ។ កាលបើដូច្នោះ បណ្តុំគ្រាប់ធម្មធាតុដែលជ្រុះចេញពីដើមគឺព្រះពុទ្ធសាសនា ដែលសទ្ធិកជនទាំងនោះលេបចូលទៅ មានប្រសិទ្ធភាពអាចកម្ចាត់បំបាត់ព្យាបាលរោគទុក្ខកង្វល់ រោគអំពើហិង្សា និងរោគវិបត្តិចិត្តសាស្ត្រជាដើម ឲ្យបានជាសះស្បើយ ព្រោះអាស្រ័យថ្នាំពោលគឺមេត្តាធម៌ ករុណាធម៌ ការគោរពការប្រតិបត្តិ និងការរក្សានូវសាសនវិធីនេះឯង ។ ការណ៍ទាំងអម្បាលម៉ាននេះ វេញចំណងយ៉ាងមាំមួន រឹតផ្តោបមហាជនឲ្យចេះគោរពគ្នា ស្រឡាញ់គ្នា មានសាមគ្គីភាព និងរក្សាសេចក្តីថ្លៃថ្នូរក្នុងសង្គម ។

អង្គការសហប្រជាជាតិក្រឡេកឃើញ **សក្តានុភាព** ឬ **សន្តិមត៌ក** របស់ព្រះពុទ្ធសាសនាត្រង់ចំណុចនេះ ទើប

ទទួលស្គាល់គុណតម្លៃនៃពុទ្ធសាសនា ហើយដាក់បញ្ចូលនូវគោលការណ៍ដ៏មានសារៈសំខាន់ទាំងនេះ ទៅក្នុងក្រឹត្យមាត្រារបស់ខ្លួន ។

**ជី២.ជម្មការៈបុជីតិការៈ** អង្គការដ៏ធំលើលោកមួយនេះបានឲ្យតម្លៃជាពិសេសមួយកម្រិតទៀត ទៅលើព្រះពុទ្ធសាសនា ដោយហេតុថា ពុទ្ធសាសនាមាននិន្នាការខាងសន្តិភាពនិយមឥតងាករេ ជាច្បាប់ធម្មនុញ្ញរបស់ពិភពលោកល្អផុតលេខ ជាកម្រងនីតិក្រមឬប្រព័ន្ធច្បាប់ប្រកបដោយសុក្រឹតភាពល្អផុតលេខ មានសុចរិតភាពឬយុត្តិធម៌ល្អផុតលេខ មានតម្លាភាពឬអព្យាក្រឹតភាពល្អផុតលេខ ។ ជាក់លាក់ណាស់ ជាគោលការណ៍ ព្រះពុទ្ធសាសនាបានប្រកាសចេញថា "ធម្មោ ហវេ រក្ខតិ ធម្មចារី =ច្បាប់តែងតែគាំពារថែរក្សានូវអ្នកគោរពនូវច្បាប់តែម្យ៉ាង" និងម្យ៉ាងទៀតថា "អព្យាបជ្ឈំ សុខំ លោកេ = ការមិនបៀតបៀនគ្នា នាំមកនូវសេចក្តីក្នុងលោក" ទុកជាសេណារិយោ(រូបមន្ត)នៃការអនុវត្តរបស់ពិភពលោក ។ ជាងនេះទៅទៀត សិទ្ធិ សេរីភាព សុខសន្តិភាព លទ្ធិប្រជាធិបតេយ្យ

និងនីតិរដ្ឋនៃសង្គមឬពិភពលោក ដែលគ្មានឃាតកម្ម ចោរកម្ម ភេរវកម្ម ឧក្រិដ្ឋកម្ម បទល្មើស អំពើហិង្សា គ្រប់រូបភាព គឺជាដើមចម **នៃសុខដុមរមនូបនីយកម្ម** មានលក្ខណៈជាសកល ជាចាំបាច់កើតឡើងក៏ព្រោះការគោរពច្បាប់ សេពគប់ច្បាប់ មិនមែនចេះតែកើតឡើងឯងៗដោយអនាធិបតេយ្យ ឬដោយឥតដើមចមនោះទេ ។ មកពីព្រះពុទ្ធសាសនា ក្រឡេកពិចារណាឃើញ នូវអំពើហិង្សា ឃាតកម្ម ចោរកម្ម ភេរវកម្មជាដើម ថាជាហេតុធ្វើឲ្យផ្សៀងនូវ**ជញ្ជីងសន្តិភាព** ដែលអូសទាញពិភពលោកទម្លាក់ក្នុងកលិយុគ**ទុក្ខូបនីយកម្ម** ហើយបំផ្លិចបំផ្លាញនូវ**សន្តិសហវិជ្ជមាន** (សេចក្តីសុខក្សេមក្សាន្តមានរួមគ្នា) ដែលជាហេតុនៃ**សុខូបនីយកម្ម** ទើបបានព្រះពុទ្ធសាសនា ប្រកាសចេញព្រះពុទ្ធមាត្រានេះឡើង ទុកជាសាធារណប្រយោជន៍ដល់ពិភពលោកទាំងអស់គ្នា ឲ្យគោរពច្បាប់ កោតក្រែងច្បាប់ យកច្បាប់ជាទង់ជ័យ យកច្បាប់ជាអធិបតី យកច្បាប់ជាស្ពានដើម្បី**សន្តិភាវូបនីយកម្ម**ជាសកល ។

ជញ្ជីងសន្តិភាព ដែលជាកម្លាំងចលករនៃសាមគ្គីភាពរបស់ពិភពលោក នឹងមិនវេទេរផ្អៀងឡើយ ដរាបណាពិភពលោកនាំគ្នាអើពើគោរពតាមនីត្យានុកូលភាព (ការអនុវត្តច្បាប់) ។

**ជី៣.ជីវសាស្ត្រលក្ខណៈ** អង្គការដ៏ធំនៅលើលោកមួយនេះ បានឲ្យតម្លៃជាពិសេស ទៅលើព្រះពុទ្ធ-សាសនាជាសាសនាមាន**សម្ពន្ធភាព**ទាក់ទងទៅនឹងធម្មជាតិពិតៗ ដែលមិនអាចកាត់ផ្តាច់ចេញពីគ្នាបានឡើយ ។ ក្នុងចំណុចនេះ ព្រះពុទ្ធសាសនា បានណែនាំឲ្យពិភពលោកចេះស្រឡាញ់ ថែរក្សា អភិរក្សនូវធនធានធម្មជាតិ រួមមានជីវៈចម្រុះ ព្រៃឈើ រ៉ែ អាកាសធាតុ បរិយាកាស និងបរិស្ថានជាដើម ឲ្យបានស្ថិតស្ថេរគង់វង្ស ហើយរហូតឈានដល់ទៅចែងនូវវិន័យក្រឹត្យឈ្មោះ**ភូតគាមសិក្ខាបទ** បញ្ញត្តចំពោះភិក្ខុណាដែលហ៊ានល្មើសកាប់ឆ្ការបំផ្លាញនូវរុក្ខជាតិ ឬព្រៃឈើជាដើមទៀត ដូចករណីរឿងអញ្ញតរភិក្ខុ ក្នុងគម្ពីរធម្មបទឆដ្ឋមភាគ នៃកោធវគ្គជា**និទស្សន៍**ស្រាប់ ។ ពីមុនមកទល់នឹងពេលបច្ចុប្បន្ននេះ សម្បត្តិធម្មជាតិទាំងអស់

ជុំវិញពិភពលោក តែងទទួលរងនូវវិនាសកម្ម ការគំរាមកំហែង ការធ្វើអាជីវកម្ម ការបំផ្លិចបំផ្លាញដោយមនុស្ស, តែឥឡូវនេះ មនុស្សក្នុងពិភពលោកក៏បែរជាទទួលរងនូវការគំរាមកំហែងពីធម្មជាតិវិញ មានជាអាទិ៍ការឡើងកម្ដៅគ្រប់តំបន់ជាសកល ការបាត់បង់ប្រព័ន្ធECOLOGY ការខូចប្រព័ន្ធអូហ្សូន(OZONE) កង្វះខាតខ្យល់អុកស៊ីសែន គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ បញ្ហាបរិស្ថាន និងការកើនឡើងនូវកម្រិតនីវ៉ូទឹកសមុទ្រជាដើម ។ ទាំងអស់នេះ គឺជាបញ្ហាចម្បងបំផុតនៃពិភពលោកទាំងមូល ជាបញ្ហារបស់យើងគ្រប់គ្នា ពុំមែនជាបញ្ហារបស់អ្នកណាម្នាក់ឡើយ ។ ដូចយើងបានឃើញស្រាប់ហើយក្នុងពេលបច្ចុប្បន្ននេះ ហាយនភាពនៃធម្មជាតិ សុទ្ធតែកើតមកពីពួកមនុស្សនិងការច្បាមយកប្រយោជន៍ហួសព្រំដែនរបស់មនុស្សទាំងអស់ អាចនិយាយបានថា មនុស្សពុំចេះស្រឡាញ់ធម្មជាតិ ឥតផ្សារខ្លួនភ្ជាប់ជាមួយធម្មជាតិ ឥតរួមគ្នាអភិរក្សធម្មជាតិឡើយ ហើយថែមទាំងនាំគ្នាបំផ្លិចបំផ្លាញធម្មជាតិដែលជារបាំងការពារខ្លួនទៅវិញ ។

តែដោយឡែក ចំពោះអង្គព្រះពុទ្ធជាម្ចាស់វិញ ទ្រង់បានផ្សារភ្ជាប់ព្រះកាយព្រះអង្គនឹងធម្មជាតិមុតមាំណាស់ ជាក់ស្តែងដូចជាការប្រសូត ការយាងចេញសាងអភិនេស្រ្កមន៍ ការត្រាស់ដឹង ការសម្តែងព្រះធម៌ប្រោសបញ្ចវគ្គិយភិក្ខុ ការធ្វើសមណធម៌នៃសាវ័កសាវិការបស់ព្រះអង្គ និងការបរិនិព្វានជាដើម ក៏ហេតុការណ៍ទាំងនេះកើតឡើងនៅក្នុងព្រៃទាំងអស់ ដែលយើងហៅថា ពុទ្ធនិយាម ។ សូម្បីតែ នៅក្នុងអនុសាសនៈ៨យ៉ាងនៃឧបសម្បទាបេក្ខភិក្ខុ មានពុទ្ធប្បញ្ញត្តិ១មាត្រាដែលថែងថា “រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជា តត្ថ តេ យាវជីវំ ឧស្សាហោ ករណីយោ = **អ្នកបួសគប្បីនៅអាស្រ័យនឹងគល់ឈើជាទីដេកទីអង្គុយ ហើយគប្បីប្រព្រឹត្តធ្វើនូវសេចក្តីព្យាយាមក្នុងទីរុក្ខមូលនោះ ដរាបដល់អស់ជីវិត**”។ សេចក្តីនេះ បានសបញ្ជាក់យ៉ាងច្បាស់ថា ក្រសែធាក ព្រះជាតិ ព្រះសាសនា ព្រះតួនាទី ព្រះធម្មប្បញ្ញត្តិ និងសូម្បីតែសាវ័ក របស់ព្រះពុទ្ធជាម្ចាស់ សុទ្ធតែបានផ្សារភ្ជាប់នឹងធម្មជាតិ ទាំងអស់ តួយ៉ាងដូចជាការប្រញប្តប្រកាស

នូវអនុសាសនៈ ១២ ទាក់ទងទៅនឹងការយកព្រៃឈើជារបាំងទីលំនៅក៏ពាក់ព័ន្ធនឹងព្រៃឈើការប្រសូតក៏នៅក្នុងព្រៃ រហូតទ្រង់យាង ចូលកាន់បរិនិព្វានជាពេលចុងក្រោយបង្អស់ក៏នៅក្នុងព្រៃដែរ នេះគឺជាការផ្ទុះបញ្ចាំងនូវជីវសម្ពន្ធភាពនៃព្រះពុទ្ធ ជាម្ចាស់ហើយ និងធម្មជាតិ ។

ព្រោះហេតុទាំង៣ ដូចបានពណ៌នាលើកឡើងមកនេះ ទើបអង្គការUNទទួលស្គាល់ដាក់បញ្ចូលធម្មនីតិរបស់ព្រះពុទ្ធសាសនា ទៅក្នុងក្រឹត្យមាត្រាខ្លួនដោយគ្មានទិរាករ។

ជាចុងបញ្ចប់នេះ សូមថ្វៃអភិលក្ខិតសម័យនៃទិវាវិសាខបូជា ជាបុណ្យពុទ្ធសាសនាបែបអន្តរជាតិដ៏ប្រកបដោយមហាបុញ្ញានុកូលភាព ប្រព្រឹត្តទៅជាកុសលប្រយោជន៍ចំពោះមហាពុទ្ធសាសនិកទាំងឡាយ នៅលើផ្ទៃរាបនៃពិភពលោក និងពពួកទេពនិករអមរមេឃ មារ ឥន្ទ្រ ព្រហ្ម ក្នុងចក្រវាឡទាំងអស់ឲ្យបាននូវសេចក្ដីសុខសេចក្ដីចម្រើន និងសិរីមង្គលសុភផលបវរសួស្ដីគ្រប់ៗគ្នា កុំបីមានការឃ្លាតក្លាយទៅ ជាបការៈដទៃអស់កាលជា

*អង្វែងទៅហោង!!!*

(សាមណេរ អគ្គសិរីវិមលញ្ញាណ **លី ម៉ុនលីន** រៀបរៀង)
លោកគ្រូព្រះមហាធម្មាលង្ការោ **ចាន់ សុជន**

# ប្រធានកម្មវិធីធាជីសំឡេងព្រះធម៌
**វត្តប្រាសាទស្រះកណ្ដាល(ខ្ទាស់)**

ចានពិនិត្យ

និងឯកភាព

*ធ្វើនៅវត្តប្រាសាទស្រះកណ្ដាល(ខ្ទាស់)*
*ថ្ងៃ១៥កើត ខែពិសាខ ព.ស២៥៥៧*
*ត្រូវនឹងថ្ងៃអង្គារ ទី១៣ ឆ្នាំ២០១៤*